ធនាគារជាតិ នៃ កម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ........................................................

# សុន្ទរកថា
## ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ថ្លែងក្នុងឱកាស អបអរសាទរខួបអនុស្សាវរីយ៍លើកទី១០៣ នៃទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០១៤
## រាជធានីភ្នំពេញ ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៤

សូមគោរព ៖

- លោកជំទាវ ទេសាភិបាលរង
- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនមន្ត្រីនារីធនាគារជាតិនៃកម្ពុជា ជាទីមេត្រី !

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដោយបានមកចូលរួមក្នុងពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១០៣ នៃទិវាអន្តរជាតិនារី ៨ មីនា ឆ្នាំ២០១៤ សម្រាប់មន្ត្រីបុគ្គលិករបស់ធនាគារជាតិនៃកម្ពុជា ។ ពិធីនៅឆ្នាំនេះ ត្រូវបានរៀបចំឡើងក្រោមប្រធានបទ "សមភាពនៃការអប់រំមានសារៈសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍សង្គម" ក្នុងគោលបំណងផ្តល់ឱកាសឱ្យបុរស ស្ត្រី ទទួលបានចំណេះដឹង ជំនាញ និងមានសីលធម៌ ដើម្បីក្លាយជាធនធានមនុស្សដ៏មានសក្តានុពលសម្រាប់ពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិ ។

ការប្រារព្ធទិវាអន្តរជាតិនារី ៨ មីនា ជាព្រឹត្តិការណ៍ប្រចាំឆ្នាំដ៏សំខាន់ ដែលបានបង្ហាញឱ្យឃើញពីសកម្មភាពរបស់បងប្អូនជនរួមជាតិកម្ពុជាយើង ក្នុងការចូលរួមប្រកបដោយឆន្ទៈមោះមុត និងជំរុញឱ្យមានការគិតគូរធ្វើសកម្មភាពឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង ព្រមទាំងបានធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសេដ្ឋកិច្ច នយោបាយ និងសង្គម រួមទាំងការលើកកម្ពស់សីលធម៌ សេចក្តីថ្លៃថ្នូរ និងតម្លៃរបស់មនុស្សផងដែរ ។

ខ្ញុំសូមគាំទ្រប្រធានបទ "សមភាពនៃការអប់រំមានសារៈសំខាន់ក្នុងកិច្ចអភិវឌ្ឍន៍សង្គម" នៃទិវាអន្តរជាតិនារីឆ្នាំនេះ ដែលផ្តោតជាសំខាន់ទៅលើការទទួលស្គាល់នូវសក្តានុពលរបស់មនុស្ស ដោយផ្តល់តម្លៃទៅលើលក្ខណៈសម្បត្តិដ៏ប្រពៃរបស់បុរស ស្ត្រី យុវវ័យ ដែលត្រូវតែមានដើម្បីជាសសរទ្រូងដ៏រឹងមាំរបស់ប្រទេសជាតិ ។ ដូចដែលគោលបំណងនៃប្រធានបទបានបញ្ជាក់ស្រាប់ ការដែលប្រជាពលរដ្ឋទាំងស្រីទាំងប្រុសទទួលបានចំណេះដឹងជំនាញ បច្ចេកទេស


ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

គ្រប់ផ្នែក គ្រប់វិស័យ ព្រមទាំងមានចិត្តគំនិត ឥរិយាបថ និងទង្វើដ៏ល្អប្រពៃអាចចូលរួមចំណែកធ្វើឱ្យប្រទេសទទួលបាននូវកិត្តិនាម កិត្តិសព្ទល្បីល្បាញ ក្នុងនាមជាប្រទេសមានប្រពៃណីវប្បធម៌ អារ្យធម៌ខ្ពស់ និងសម្បូររុងរឿងនៅលើឆាកអន្តរជាតិ ។

ថ្ងៃនេះ ខ្ញុំសង្កេតឃើញថា បងប្អូននារីយើងមានទឹកមុខរីករាយ ស្រស់ថ្លា និងញញឹមញញែមប្រកបដោយសេចក្តីសង្ឃឹមជានិច្ច ។ ខ្ញុំសូមចូលរួមអបអរសាទរយ៉ាងខ្លាំងក្លាចំពោះស្នាដៃនារី និងសូមប្រសិទ្ធពរជ័យ បវរសួស្តី វិបុលសុខ មហាប្រសើរគ្រប់យ៉ាង ចំពោះ លោកជំទាវថ្នាក់ដឹកនាំ និងបងប្អូននារីធនាគារជាតិនៃកម្ពុជាទាំងអស់ សមប្រកបតែនឹងកាយពលមាំមួនប្រាជ្ញាវាងវៃ សុខភាពល្អ និងទទួលបានជ័យជម្នះគ្រប់ភារកិច្ច ។

ពិធីអបអរសាទរទិវានារីអន្តរជាតិ ៨ មីនា នេះត្រូវបានប្រារព្ធធ្វើឡើងនៅទូទាំងសកលលោក ដើម្បីរំឭកពីប្រវត្តិនៃការតស៊ូនិងវីរភាពរបស់នារី ដែលបានខិតខំតស៊ូទាមទារនូវសមធម៌ ការគោរពសិទ្ធិសេរីភាពស្មើគ្នាចំពោះមុខច្បាប់ និងការទទួលស្គាល់តម្លៃស្ត្រីក្នុងការអភិវឌ្ឍគ្រួសារ និងជាពិសេស ដើម្បីអបអរសាទរសមិទ្ធផលផ្នែកសេដ្ឋកិច្ច នយោបាយ និងវប្បធម៌ ដែលនារីបានរួមចំណែកកសាងនិងអភិវឌ្ឍជូនប្រទេសជាតិនិងមាតុភូមិយើងកន្លងមក ។ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល ធនាគារជាតិនៃកម្ពុជាយើងតែងតែប្រារព្ធពិធីនេះជារៀងរាល់ឆ្នាំផងដែរ ដើម្បីលើកកម្ពស់ និងថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និងមន្ត្រីបុគ្គលិកជានារីនៅធនាគារជាតិនៃកម្ពុជា ដែលបានរួមចំណែកកសាងនិងអភិវឌ្ឍប្រព័ន្ធធនាគារនៅកម្ពុជាឱ្យមានការរីកចម្រើនជាបន្តបន្ទាប់ ។

**- គណៈអធិបតី ជាទីគោរព !**

**- បងប្អូនមន្ត្រីនារី ជាទីមេត្រី !**

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំសូមរំលឹកពីប្រវត្តិនិងវីរភាពនៃការតស៊ូរបស់នារី ការទទួលខុសត្រូវ និងតម្លៃនារីនៅក្នុងសង្គមនិងគ្រួសារខ្មែរ ក៏ដូចជាក្នុងការងារនយោបាយដើម្បីរួមចំណែកអភិវឌ្ឍប្រទេសជាតិ ដូចខាងក្រោម ៖

នៅប្រទេសកម្ពុជា បើតាមប្រវត្តិសាស្ត្របានបញ្ជាក់ថា ស្ត្រីមានសារៈសំខាន់ណាស់ចំពោះសង្គមនិងគ្រួសារ ។ ព្រះនាងលីវយី គឺជាព្រះមហាក្សត្រីយានី និងជាស្ត្រីទី១ ដែលគ្រប់គ្រងនិងដឹកនាំប្រទេសកម្ពុជា ។ បន្ទាប់មក នៅសម័យអង្គរ ព្រះនាងឥន្ទ្រទេវី ជាអគ្គមហេសីព្រះបាទជ័យវរ្ម័នទី៧ និងជាស្ត្រីដែលមានប្រាជ្ញាឈ្លាសវៃ បានជួយការងារសង្គម និងជ្រោមជ្រែងព្រះបាទជ័យវរ្ម័នទី៧ ជាស្វាមី ដឹកនាំប្រទេសកម្ពុជាទទួលបានជោគជ័យ និងមានកេរ្តិ៍ឈ្មោះល្បីរន្ទឺ ក្នុងប្រវត្តិសាស្ត្រកម្ពុជារហូតមកដល់សព្វថ្ងៃនេះ ។ និយាយជារួម វប្បធម៌ខ្មែរយើងយើងគោរពនារី ផ្តល់តម្លៃចំពោះនារី យកនារីជាធំនៅក្នុងសង្គមនិងគ្រួសារ ព្រមទាំងបាន

ចាត់ទុក នារីជាមាតានៃប្រទេសជាតិតាំងពីយូរលង់ណាស់មកហើយ តាមរយៈពាក្យបុរាណពោលថា " មេទ័ព " " មេបា " និង " មាតុភូមិ ឬ មាតុប្រទេសកម្ពុជា " ជាដើម ។ ជាទូទៅស្ត្រីគឺជាមាតាដ៏ល្អ និងជាមេផ្ទះដ៏ប្រពៃ ដែលចេះថៃទាំអប់រំកូនឱ្យក្លាយជាពលរដ្ឋល្អ ។

បច្ចុប្បន្ន ស្ត្រីមានចំនួនពាក់កណ្តាលនៃប្រជាជនសរុបក្នុងប្រទេសកម្ពុជា ហើយបានជួយរំលែកបន្ទុកគ្រួសារ សង្គម និងរួមចំណែកកសាងនិងអភិវឌ្ឍប្រទេសជាតិជាច្រើន ។ ជាពិសេស តាមរយៈការងារកាកបាទក្រហមកម្ពុជា ក្រោមការដឹកនាំរបស់ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន ប្រធានកាកបាទក្រហមកម្ពុជា និងការខិតខំប្រឹងប្រែងរបស់សម្តេចកិត្តិព្រឹទ្ធបណ្ឌិតផ្ទាល់ បានជួយទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារមកលើស្ត្រីនិងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ ការប្រយុទ្ធប្រឆាំងគ្រឿងញៀន និងជួយកុមារកំព្រាជាដើម ធ្វើឱ្យបុត្រធីតានិងយុវវ័យមានឱកាសចូលរួមចំណែកទទួលខុសត្រូវលើរាល់សកម្មភាពក្នុងគ្រួសារនិងសង្គម ទទួលបានការអប់រំ ការកសាង និងការពង្រឹងសមត្ថភាពខ្លួនឯង សំដៅធ្វើខ្លួនឱ្យក្លាយទៅជាកូនល្អ មិត្តល្អ សិស្សល្អ មិនប្រើអំពើហិង្សា មិនសេពគ្រឿងញៀន រួមចំណែកជានាសណ្តាប់ធ្នាប់សង្គម និងចូលរួមអភិវឌ្ឍជាតិមាតុភូមិជាទីស្នេហារបស់យើង និងជាពិសេស បានធ្វើឱ្យតម្លៃស្ត្រី និងសីលធម៌សង្គមត្រូវបានលើកតម្កើងជាលំដាប់ ទាំងក្នុងវេទិកាជាតិនិងអន្តរជាតិ ។ ខ្ញុំសង្កេតឃើញថា ស្ត្រីចេះអភិវឌ្ឍនិងលើកកម្ពស់ខ្លួនឯង ដើម្បីចូលប្រឡូកក្នុងគ្រប់កិច្ចការសង្គម ចាប់តាំងពីកម្មកររហូតដល់មានឋានៈនិងតួនាទីខ្ពស់នៅក្នុងជួររដ្ឋាភិបាល រដ្ឋសភា និងព្រឹទ្ធសភាជាដើម ។

ដោយឡែក នៅធនាគារជាតិនៃកម្ពុជាយើងវិញបច្ចុប្បន្ន មានមន្ត្រីបុគ្គលិកសរុបទូទាំងប្រទេសចំនួន ១.៣៤៧នាក់ ក្នុងនោះថ្នាក់ដឹកនាំនិងមន្ត្រីបុគ្គលិកជានារីមានចំនួន ៦០១នាក់ ។ ចំនួននេះបញ្ជាក់ថា សមាមាត្រមន្ត្រីបុគ្គលិកជាស្ត្រីចាប់តាំងពីថ្នាក់ទេសាភិបាលរងដល់បុគ្គលិកធម្មតាកើនដល់ ៤៥% នៃចំនួនសរុប ក្នុងនោះ ចំនួនស្ត្រីក្នុងជួរថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជាបានកើនឡើង ៣៥% នៃចំនួនសរុប ។ ស្ត្រីនៅធនាគារជាតិនៃកម្ពុជាភាគច្រើនទទួលខុសត្រូវលើការងារដឹកនាំនិងគ្រប់គ្រងការងារជំនាញបច្ចេកទេស និងការងារប្រតិបត្តិការជាដើម ។ សមាមាត្រដ៏ធំនេះបានបង្ហាញឱ្យឃើញអំពីសមត្ថភាព ការលើកកម្ពស់ស្ត្រី និងសារៈសំខាន់របស់ស្ត្រីចំពោះការងារ ព្រមទាំងមានការជឿជាក់ក្នុងការបំពេញតួនាទីភារកិច្ច នៅគ្រប់លំដាប់ថ្នាក់នៃការគ្រប់គ្រងធនាគារ ។

**- គណៈអធិបតី ជាទីគោរព !**

**- បងប្អូនមន្ត្រីនារី ជាទីមេត្រី !**

នៅក្នុងឱកាសដ៏ប្រសើរថ្លៃថ្លានេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរជាថ្មីម្តងទៀតដល់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហា

សេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានគោលនយោបាយ និងយុទ្ធសាស្ត្រ ផ្តោតយ៉ាងជាក់លាក់ទៅលើការលើកកម្ពស់សមភាពយេនឌ័រ និងការអភិវឌ្ឍធនធានមនុស្ស ដែលគ្រប់ក្រសួង-ស្ថាប័នកំពុងអនុវត្តដើម្បីប្រជាពលរដ្ឋកម្ពុជា ជាពិសេសស្ត្រីនិងយុវវ័យបានរួមចំណែកអភិវឌ្ឍប្រទេសឱ្យឈានឆ្ពោះទៅរកភាពចម្រើនរុងរឿង មានជាអាទិ៍ ការធ្វើឱ្យប្រសើរឡើងនូវកំណើនសេដ្ឋកិច្ច ការរក្សានូវសន្តិភាព ស្ថិរភាពនយោបាយ និងសន្តិសុខសង្គម ព្រមទាំងការលើកកម្ពស់សិទ្ធិ សេចក្តីថ្លៃថ្នូរ និងសីលធម៌ផងដែរ ។ ការបង្កើតគណៈកម្មាធិការជាតិ លើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ដែលមានសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា ជាប្រធានកិត្តិយស និងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ដែលមាន សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល ជាប្រធានកិត្តិយស និងសម្តេចតេជោនាយករដ្ឋមន្ត្រី ជាអនុប្រធានកិត្តិយស ក៏ជាចំណែកមួយក្នុងការលើកកម្ពស់ស្ថានភាពស្ត្រី តម្លៃស្ត្រី រួមទាំងសីលធម៌សង្គម និងវប្បធម៌ប្រពៃណីដ៏ល្អផូរផង់របស់កម្ពុជាយើង ។

តាមរយៈយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាលបានចាត់ទុកតួនាទីស្ត្រីគឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចនិងសង្គមជាតិ ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលក៏បានបង្កើតផែនការយុទ្ធសាស្ត្រនារីរតនៈ ដើម្បីជំរុញការលើកកម្ពស់តួនាទីរបស់ស្ត្រីនៅក្នុងសេដ្ឋកិច្ច និងសង្គមខ្មែរ លើកកម្ពស់សុខុមាលភាពស្ត្រី ការអប់រំដល់ស្ត្រីនៅគ្រប់កម្រិតឱ្យចូលរួមកាន់តែសកម្មក្នុងរដ្ឋបាលសាធារណៈ ការពង្រឹងការឈរឈ្មោះនៅតាមបណ្តាភូមិ ឃុំ សង្កាត់ទូទាំងប្រទេស ព្រមទាំងការពង្រឹងឱកាសការងារនិងការពារសិទ្ធិធ្វើការងារសម្រាប់ស្ត្រី ។

ស្របតាមប្រធានបទខួបអនុស្សាវរីយ៍លើកទី១០៣ ទិវាអន្តរជាតិនារីឆ្នាំនេះ ដែលផ្តោតជាសំខាន់ទៅលើការអប់រំរបស់ស្ត្រី ដើម្បីរួមចំណែកពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ការអភិវឌ្ឍធនធានមនុស្ស នៅធនាគារជាតិនៃកម្ពុជា ត្រូវបានចាត់ទុកជាគន្លឹះក្នុងការងារប្រចាំថ្ងៃ ដោយផ្អែកលើគោលការណ៍សមភាពមន្ត្រីបុគ្គលិកបុរសនិងនារី ដើម្បីរក្សានិរន្តរភាពការងារ និងក្នុងការជំរុញការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា ។ កន្លងមកការបណ្តុះបណ្តាលធនធានមនុស្សនៅធនាគារជាតិនៃកម្ពុជា ត្រូវបានធ្វើឡើង ក្រោមទម្រង់ជាការចាត់បញ្ជូនមន្ត្រីបុគ្គលិកចូលរួមសិក្ខាសាលានៅក្រៅប្រទេសជាប់ជាប្រចាំ ព្រមទាំងចែករំលែកចំណេះដឹងនិងបទពិសោធន៍មន្ត្រីបុគ្គលិកដទៃទៀត ។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាយើងក៏បានរៀបចំនូវវគ្គបណ្តុះបណ្តាលមានលក្ខណៈជា In-House Training ជាច្រើនលើកមកហើយ ដោយប្រើធនធានផ្ទាល់របស់ធនាគារជាតិនៃកម្ពុជា និងមានការចូលរួមធ្វើ

បទឧទ្ទេសនាមពីលោកជំនាញការប្រចាំធនាគារជាតិនៃកម្ពុជា មន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញជាច្រើនដែលធ្លាប់ទទួលបានការបណ្តុះបណ្តាលនេះនៅក្រៅប្រទេស ។

មុននឹងបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅនិងកោតសរសើរខ្លាំងចំពោះថ្នាក់ដឹកនាំនារី និងមន្ត្រីបុគ្គលិកនារីធនាគារជាតិនៃកម្ពុជា ដែលបាននិងកំពុងខិតខំប្រឹងប្រែងជំរុញការលើកកម្ពស់សមភាពយេនឌ័រ ដើម្បីស្ត្រីបានទទួលនូវកិច្ចការពារសិទ្ធិនិងផលប្រយោជន៍តាមរយៈការកែប្រែឥរិយាបថសង្គមឱ្យទទួលស្គាល់ និងចាត់ទុកស្ត្រីជាដៃគូដ៏សំខាន់ក្នុងការអភិវឌ្ឍគ្រួសារនិងសង្គម ដោយជួយជំរុញការកសាងនិងអភិវឌ្ឍសមត្ថភាពស្ត្រី ក៏ដូចជាការផ្តល់ឱកាសឱ្យស្ត្រីចូលរួមប្រកបដោយសមធម៌ក្នុងគ្រប់ការងារនិងក្នុងគ្រប់វិស័យ ។

ខ្ញុំសូមប្រសិទ្ធពរជ័យ សិរីសួស្តី ចំពោះមន្ត្រីបុគ្គលិកនារីធនាគារជាតិនៃកម្ពុជានៅទូទាំងប្រទេស សូមបានប្រកបតែនឹងសេចក្តីសុខ សេចក្តីចម្រើនគ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ ។ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះលោកជំទាវ ឯកឧត្តម លោក លោកស្រី និងនាងកញ្ញាទាំងអស់ដែលបានចូលរួមក្នុងពិធីយើងថ្ងៃនេះ និងសូមជូនពរឱ្យជួបប្រទះតែពុទ្ធពរទាំង ៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ**